**MASSACHUSETTS COVID-19 VACCINE PROGRAM**

# វ៉ាក់សាំងកូវីដ-19៖ សំណួរបានសួរជាញឹកញាប់

បានធ្វើឲ្យបច្ចុប្បន្នភាព ថ្ងៃទី7 ខែកញ្ញា ឆ្នាំ2021

សំណួរបានសួរជាញឹកញាប់វ៉ាក់សាំងកូវីដ-19 | Mass.gov

**តារាងមាតិកា**


- មុននឹងទទួលវ៉ាក់សាំង
- ក្នុងកំឡុងពេលការណាត់ជួបរបស់អ្នក
- ក្រោយ ពីទទួលវ៉ាក់សាំង
- សុវត្ថិភាពវ៉ាក់សាំង
- ព័ត៌មានបន្ថែម


## មុននឹងទទួលវ៉ាក់សាំង

**តើខ្ញុំនឹងបង់ថ្លៃសម្រាប់វ៉ាក់សាំងឬទេ?**

ទេ ។ វ៉ាក់សាំង ត្រូវបានផ្តល់ដោយមិនអស់លុយចំពោះបុគ្គលគ្រប់រូប ដោយរដ្ឋាភិបាលសហព័ន្ធ ។ ប្រសិនបើអ្នកមានការធានារ៉ាប់រង គេនឹងផ្ញើវិក័យបត្រទៅការធានារ៉ាប់រងរបស់អ្នក ។ ប៉ុន្តែ អ្នកមិនចាំបាច់ មានការធានារ៉ាប់រង ដើម្បីទទួលវ៉ាក់សាំងទេ ។ អ្នកនឹងមិនត្រូវបានស្នើសុំលេខកាតឥណទាន ដើម្បីធ្វើការណាត់ជួបទេ ។

**តើជនភៀសខ្លួន ដែលគ្មានក្រដាសស្នាមទទួលបានវ៉ាក់សាំង ដោយមិនអស់លុយ ?**

មែនហើយ។ វ៉ាក់សាំងគឺមិនអស់លុយសម្រាប់បុគ្គលគ្រប់រូបក្នុងរដ្ឋម៉ាសាជូសេត្ស ។ ការធានារ៉ាប់រងសុខភាព (រួមជាមួយ Medicare និង Medicaid) នឹង រ៉ាប់រង តម្លៃនៃការផ្តល់ ថ្នាំវ៉ាក់សាំង ។ សម្រាប់អ្នកជម្ងឺដែលគ្មាន ការធានារ៉ាប់រងសុខភាព អ្នកផ្តល់សេវាថែទាំសុខភាពអាចស្នើសុំសំណងពីរដ្ឋាភិបាលសហព័ន្ធ សម្រាប់តម្លៃនៃការផ្តល់វ៉ាក់សាំងសម្រាប់ជនភៀសខ្លួនគ្មានក្រដាសស្នាម ។

**តើខ្ញុំអាចនៅតែទទួលវ៉ាក់សាំង ប្រសិនបិនខ្ញុំមិនមានប័ណ្ណអែឌី ?**

មែនហើយ ។ អ្នកអាចទទួលវ៉ាក់សាំងព្រមទាំងប្រសិនបើអ្នកគ្មានការរ៉ាប់រង ប័ណ្ណបើកឡាន ឬលេខសន្តិសុខសង្គមទៀតផង ។ សម្រាប់ព័ត៌មានបន្ថែមសូមចូលរបៀបដើម្បីរៀបចំសម្រាប់ការណាត់ជួបវ៉ាក់សាំងកូវីដ-19។

**តើការទទួលវ៉ាក់សាំងនឹងប៉ះទង្គិចអវិជ្ជមានចំពោះស្ថានភាព អន្តោប្រវេសន៍របស់បុគ្គលឬទេ ?**

ទេ។ រដ្ឋាភិបាលសហព័ន្ធបានបញ្ជាក់ថាខ្លួននឹងមិនពិចារណាលើការព្យាបាលដោយកូវីដ-19 (រួមទាំងវ៉ាក់សាំង) ដែលជាផ្នែកមួយនៃការសំរេចថា តើនរណាម្នាក់ជា “ថ្លៃសេវាសាធារណៈ” ឬដោយសារវាទាក់ទងនឹងលក្ខខណ្ឌផលប្រយោជន៍សាធារណៈ សម្រាប់បុគ្គលជាក់លាក់ដែលស្វែងរកការពន្យារពេលនៃការស្នាក់នៅ ឬការផ្លាស់ប្តូរស្ថានភាពទោះបីជាវ៉ាក់សាំងត្រូវបានបង់ដោយ Medicaid ឬមូលនិធិសហព័ន្ធផ្សេងទៀតក៏ដោយ ។

**តើកំណត់ត្រាថ្នាំវ៉ាក់សាំងរបស់អ្នកជម្ងឺ ការពារគេពីការបញ្ចេញ ឈ្មោះរបស់គេឬទេ ?**

ក្រសួងសុខាភិបាលសាធារណៈ នឹងរក្សាទុកកំណត់ត្រាអេឡិចត្រូនិច នៃអ្នកជម្ងឺម្នាក់ៗក្នុងរដ្ឋម៉ាសាជូស្សេតស៍ ដែលទទួលវ៉ាក់សាំងកូវីដ-19 ។ ឃ្លាំងផ្ទុកទិន្នន័យ គឺត្រូវបានរក្សាទុកសម្ងាត់ដូចជាកំណត់ត្រាវេជ្ជសាស្ត្រ របស់អ្នកជម្ងឺជាមួយវេជ្ជបណ្ឌិតរបស់គាត់ ។

**តើខ្ញុំនឹងត្រូវបានតេស្តសម្រាប់កូវីដ-19 មុននឹងទទួលវ៉ាក់សាំងឬទេ ?**
ទេ តេស្តកូវីដ-19 គឺត្រូវបានចាំបាច់មុននឹងទទួលវ៉ាក់សាំងឡើយ ។

**តើអ្នកដែលមានវិជ្ជមានកូវីដ-19 គួរតែទទួលវ៉ាក់សាំងឬទេ ?**
អត់ទេ។ បុគ្គល ដែលត្រូវបានគេដឹងថាមានកូវីដ-19 គួរតែរង់ចាំទទួលការចាក់វ៉ាក់សាំង រហូតដល់រយៈពេលការញែកខ្លួនរបស់ពួកគេបានបញ្ចប់ជាធម្មតា 10 ថ្ងៃ បន្ទាប់ពីរោគសញ្ញាចាប់ផ្តើម ឬប្រសិនបើពួកគេមិនមានរោគសញ្ញា 10 ថ្ងៃ ក្រោយការធ្វើតេស្តរបស់ពួកគេវិជ្ជមាន ។

**តើបុគ្គលដែលមានកូវីដ-19 រួចហើយគួរតែទទួលវ៉ាក់សាំងឬទេ ?**
បាទ/ចាស់ តើបុគ្គលដែលមានកូវីដ-19 រួចហើយគួរតែទទួលវ៉ាក់សាំង ។
ក្រុមអ្នកជំនាញមិនទាន់ដឹងថា
តើអ្នកត្រូវបានការពារពីការឈឺម្តងទៀតយូរប៉ុណ្ណាបន្ទាប់ពីបានជាសះស្បើយពី កូវីដ-19 ។
ទោះបីជាអ្នកបានជាសះស្បើយពីកូវីដ-19
រួចហើយក៏ដោយទោះបីវាកម្រក៏ដោយក៏អ្នកអាចឆ្លងវីរុសដែលបណ្តាលឱ្យមានកូវីដ-19
ម្តងទៀតដែរ ។

**តើបុគ្គលដែលរស់ក្នុងរដ្ឋ ឬប្រទេសពាក់កណ្តាលម៉ោង (ឧ. សិស្ស អ្នកចូលនិវត្ត បុគ្គលដែលមានសញ្ជាតិទ្វេពីរ អាចទទួលវ៉ាក់សាំងកូវីដ-19 ក្នុងម៉ាសាជូសេត្សឬទេ ?**
មែនហើយ ។ កម្មវិធីចាក់ថ្នាំវ៉ាក់សាំងកូវីដ-19 រដ្ឋម៉ាសាជូស្សេតស៍ គឺសម្រាប់បុគ្គលដែលរស់នៅ ធ្វើការឬសិក្សាក្នុងចំណោមប្រជាពលរដ្ឋ ។ អ្នកក៏អាចទទួលកម្រិតទីពីរក្នុងរដ្ឋម៉ាសាជូស្សេតស៍ ប្រសិនបើអ្នកបានទទួលកម្រិតទីមួយក្នុងរដ្ឋមួយទៀត ។ សូមបញ្ជាក់ថារក្សាទុកប័ណ្ណចាក់ថ្នាំវ៉ាក់សាំង ដែលអ្នកបានទទួលនៅពេលបានទទួលវ៉ាក់សាំងដំបូង ។

**តើការទទួលវ៉ាក់សាំងកូវីដ-19 មានអត្ថប្រយោជន៍អ្វីខ្លះ ?**
ការចាក់ថ្នាំវ៉ាក់សាំងកូវីដ-19 នឹងជួយការពារអ្នកពីការកើតកូវីដ-19 ។ កូវីដ-19 វ៉ាក់សាំងទាំងអស់ ដែលមានដល់ក្នុងសហរដ្ឋអាមេរិកមានប្រសិទ្ធិភាពខ្ពស់ ។ អ្នកឯកទេសបន្តធ្វើការសិក្សាស្រាវជ្រាវបន្ថែមដោយចង់ដឹងថា តើវ៉ាក់សាំងក៏នឹងជួយបុគ្គលពីការចម្លងកូវីដ-19 ឬអត់ ។ ការពាក់ម៉ាសនិងចម្ងាយខាងសង្គម ជួយកាត់បន្ថយ ឱកាសរបស់អ្នកពីវីរុស ឬការចម្លងវាទៅអ្នកដទៃទៀត ប៉ុន្តែវិធានការទាំងនេះ មិនគ្រប់គ្រាន់ទេ ការចាក់វ៉ាក់សាំង និងធ្វើតាមអនុសាសន៍របស់ CDC ទាំងពីរ ការពារអ្នកនិងអ្នកដទៃ នឹងផ្តល់នូវការការពារល្អបំផុតពីកូវីដ-19 ។

**តើវ៉ាក់សាំងនឹងដំណើរការប្រឆាំងនឹងការផ្លាស់ប្តូររបស់កូវីដ-19 ដូចជាការផ្លាស់ប្តូរមួយនៅប្រទេសអង់គ្លេសឬទេ ?**
វាធម្មតាទេ ចំពោះវីរុសដើម្បីផ្លាស់ប្តូរក្នុងអំឡុងពេលវារីករាលដាល ហើយចំពោះវីរុស ថ្មីដើម្បីនឹងលេចចេញមក ។ អ្នកវិទ្យាសាស្ត្រកំពុងធ្វើការដើម្បីរៀនបន្ថែមទៀត ថាតើវ៉ាក់សាំងដែលយើងមានរួចទៅហើយ នឹងការពារបុគ្គលពីការផ្លាស់ប្តូរកូវីដ-19 ឬអត់ ។ វ៉ាក់សាំង Janssen (Johnson & Johnson) ត្រូវបានសិក្សាស្រាវជ្រាវក្នុងប្រទេសជាច្រើន រួមទាំងប្រទេសអាហ្វ្រិកខាងត្បូង និងប្រាសៀល ដែលជាទីកន្លែងទាំងពីរដែលមានកូវីដ-19 បានលេចចេញមក ។ រហូតដល់មកដល់ពេល នេះ ការសិក្សាបង្ហាញថា វ៉ាក់សាំងដែលមានការអនុញ្ញាតពេលនេះ ផ្តល់នូវការការពារ ពីការផ្លាស់ប្តូរនៃកូវីដ ។

**តើវ៉ាក់សាំងកូវីដ-19 Johnson & Johnson ផ្តល់ការការពារដូចជាវ៉ាក់សាំង Pfizer និង Moderna ឬទេ ?**
វ៉ាក់សាំងកូវីដ-19 អនុម័តទាំងបីមានសុវត្ថិភាព និងមានប្រសិទ្ធិភាពខ្ពស់ប្រឆាំង នឹងរោគធ្ងន់ធ្ងរ ការសម្រាកក្នុងមន្ទីរពេទ្យនិងសេចក្តីស្លាប់ ។ វ៉ាក់សាំង Janssen (Johnson & Johnson) ផ្តល់នូវការការពារ 93% ប្រឆាំងពីការសម្រាកនៅមន្ទីរពេទ្យមកពីកូវីដ-19 ។ វាក៏ត្រូវបានបង្ហាញទៀតថាវាមានប្រសិទ្ធិភាពប្រឆាំងនឹងការផ្លាស់ប្តូរកូវីដ-19 ថ្មី ជាមួយការស្រាវជ្រាវ បានធ្វើឡើងក្នុងពហុប្រទេស ជាមួយការផ្លាស់ប្តូរកាន់តែចម្លង រួមទាំងប្រទេសអាហ្វ្រិក និងប្រទេសប្រាសៀល ។ អត្ថប្រយោជន៍បន្ថែមគឺថាវ៉ាក់សាំង Janssen (Johnson & Johnson) តម្រូវឱ្យមានការចាក់តែមួយដង ដូច្នេះប្រសិនបើអ្នកត្រូវបានផ្តល់ដល់អ្នកគឺ "បានធ្វើរួច" ហើយអ្នកមិនចាំបាច់ធ្វើការណាត់ជួបលើកទីពីរទេ ។

**តើការអនុញ្ញាតសម្រាប់ការប្រើប្រាស់បន្ទាន់គឺជាអ្វី ?** (បានធ្វើបច្ចុប្បន្នភាព 9/7/21)
ថ្នាំវ៉ាក់សាំងបីប្រភេទ – Pfizer, Moderna, និង Janssen (Johnson & Johnson) – បានទទួលការអនុញ្ញាតសម្រាប់ការប្រើប្រាស់បន្ទាន់ (Emergency Use Authorization, EUA) ពីរដ្ឋបាលអាហារ និងឱសថសហព័ន្ធ ។ Pfizer ក៏ទទួលបានការឯកភាពសម្រាប់មនុស្សដែលមានអាយុ 16ឆ្នាំឡើងទៅ។ ដើម្បីស្វែងយល់បន្ថែមទៀតថាតើនេះមានន័យដូចម្តេច – និងព័ត៌មានបន្ថែមដទៃទៀតអំពីវ៉ាក់សាំង – ក្នុងព្រឹត្តិបត្រព័ត៌មាន FDA សម្រាប់អ្នកទទួលនិងអ្នកផ្តល់ការថែទាំរបស់ពួកគេ៖ Comirnaty/Pfizer, Moderna, និង Johnson & Johnson (Janssen)។

**ដោយសារតើវ៉ាក់សាំងកូវីដ-19 Pfizer មានការឯកភាពរបស់ FDA ដូច្នេះតើវាមានន័យដូចម្តេច?** (បច្ចុប្បន្នភាព 9/7/21)
នៅថ្ងៃទៅ23 ខែសីហា ឆ្នាំ2021 រដ្ឋបាលចំណីអាហារនិងឱសថរបស់សហរដ្ឋអាមេរិក (FDA) បានឯកភាពលើវ៉ាក់សាំងកូវីដ-19 ជាលើកដំបូង។ វ៉ាក់សាំងនេះត្រូវបានស្គាល់ថាជាវ៉ាក់សាំងកូវីដ-19 Pfizer ហើយនឹងត្រូវបានផ្សព្វផ្សាយថាជា Comirnaty (koe-mir’-na-tee) នៅពេលនេះសម្រាប់ការបង្កាជំងឺកូវីដ-19 ចំពោះមនុស្សដែលមានអាយុ 16ឆ្នាំឡើងទៅ។ Comirnaty គឺដូចគ្នាទៅនឹងវ៉ាក់សាំង Pfizer ដែរ។ វ៉ាក់សាំង Pfizer ក៏នៅតែមានផ្តល់ជូនក្រោមការអនុញ្ញាតឲ្យប្រើប្រាស់បន្ទាន់ (EUA) សម្រាប់មនុស្សដែលមានអាយុ 12ឆ្នាំដល់ 15ឆ្នាំ។

បើធៀបទៅនឹង EUA ការឯកភាពរបស់ FDA ទៅលើវ៉ាក់សាំងគឺតម្រូវឲ្យមានទិន្នន័យបន្ថែមទៀតស្តីពីសុវត្ថិភាព ការផលិត និងប្រសិទ្ធភាពក្នុងរយៈពេលវែងជាងនេះ និងរួមបញ្ចូលទិន្នន័យជាក់ស្តែង។ ការអនុញ្ញាតពេញលេញដោយ FDA មានន័យថាវ៉ាក់សាំង Comirnaty នៅពេលនេះមានកម្រិតនៃការឯកភាពដូចគ្នាទៅនឹងវ៉ាក់សាំងផ្សេងទៀតដែលបានប្រើប្រាស់ជាប្រចាំនៅក្នុងសហរដ្ឋអាមេរិក ដូចជាវ៉ាក់សាំងសម្រាប់ជំងឺថ្លើម កញ្ជ្រឹលអុតស្វាយ និងគ្រុនស្វិតដៃជើង។ វ៉ាក់សាំងកូវីដ-19 Pfizer គឺជាវ៉ាក់សាំងដំបូងដែលទទួលបានការអនុញ្ញាតឲ្យប្រើប្រាស់បន្ទាន់ ដែលនោះជាមូលហេតុធ្វើឲ្យវាក្លាយជាវ៉ាក់សាំងដំបូងដែលមានទិន្នន័យគ្រប់គ្រាន់ក្នុងការទទួលបានការឯកភាពពេញលេញ។ វាមិនមានន័យអ្វីជាប់ពាក់ព័ន្ធនឹងសុវត្ថិភាពនិងប្រសិទ្ធភាពនៃវ៉ាក់សាំង Moderna ឬ Johnson & Johnson។

## ក្នុងអំឡុងពេលការណាត់ជួប

**តើខ្ញុំអាចរំពឹងដូចម្តេចនៅឯការណាត់ជួបរបស់ខ្ញុំដើម្បីទទួលបានវ៉ាក់សាំងសម្រាប់កូវីដ-19 ?**
សូមចូលទៅ [តើអាចរំពឹងដូចម្តេចនៅឯការណាត់ជួបរបស់អ្នកដើម្បីទទួលបានវ៉ាក់សាំងសម្រាប់កូវីដ-19 | CDC] សម្រាប់ចំណុចសំខាន់ស្តីពីអ្វីដែលអ្នករំពឹងនៅពេលអ្នកចាក់វ៉ាក់សាំង តើព័ត៌មានអ្វីខ្លះដែលអ្នកផ្តល់សេវារបស់អ្នកនឹងផ្តល់ឱ្យអ្នកនិងធនធានដែលអ្នកអាចប្រើដើម្បីតាមដានសុខភាពរបស់អ្នកបន្ទាប់ពីអ្នកបានទទួលថ្នាំវ៉ាក់សាំងរួច ។

**តើខ្ញុំត្រូវពាក់ម៉ាសឬទេនៅពេលខ្ញុំទទួលវ៉ាក់សាំងកូវីដ-19 ?**

បាទ/ចាស៎ អ្នកត្រូវតែពាក់ម៉ាសដែលគ្របលើច្រមុះ និងមាត់របស់អ្នកក្នុងអំឡុងពេលការណាត់ជួបរបស់អ្នក ។

**តើខ្ញុំត្រូវរង់ចាំរយៈពេលប៉ុន្មាននៅក្នុងចន្លោះពេល នៃកម្រិតទី 1 និងទី 2 នៃ វ៉ាក់សាំងកូវីដ-19 សម្រាប់ Pfizer និង Moderna ?** (បានធ្វើបច្ចុប្បន្នភាព 8/18/21)
ការចាក់ថ្នាំ **ទីពីររបស់អ្នកត្រូវបានផ្តល់ជាអនុសាសន៍ នៅចំនួន 21 ថ្ងៃ សម្រាប់ Pfizer និង ចំនួន 28 ថ្ងៃ សម្រាប់ Moderna** ប៉ុន្តែ ប្រសិនបើអ្នកទទួលបានការចាក់លើកទី 2 នៅពេលណាមួយបន្ទាប់ពីកាលបរិច្ឆេទដែលបានណែនាំ អ្នកនៅតែត្រូវបានគេចាត់ទុកថាអ្នកទទួលបានការចាក់វ៉ាក់សាំងពេញលេញ។ អ្នកមិនត្រូវទទួលកម្រិតទីពីរមុននឹង ចំនួន 21 ថ្ងៃសម្រាប់ Pfizer ឬចំនួន 28 ថ្ងៃសម្រាប់ Moderna។ វ៉ាក់សាំង Janssen (Johnson & Johnson) គឺសម្រាប់មួយកម្រិតប៉ុណ្ណោះ ។

**តើវ៉ាក់សាំង Pfizer ឬវ៉ាក់សាំងកូវីដ-19 Moderna មួយកម្រិតមានប្រសិទ្ធភាពយ៉ាងណាបើប្រៀបធៀបនឹងពីរកម្រិត ?**
វ៉ាក់សាំង Pfizer និង Moderna COVID-19 មិនត្រូវបានសិក្សាស្រាវជ្រាវសម្រាបតែមួយកម្រិតនោះទេ ។ បុគ្គលគួរតែទទួលវ៉ាក់សាំងទាំងពីរកម្រិត ដើម្បីត្រូវបានវ៉ាក់សាំងពេញលេញ ។

**តើខ្ញុំនឹងត្រូវបានគេតាមដានក្រោយពីទទួលវ៉ាក់សាំងឬទេ ?**
បុគ្គលដែលមានប្រវត្តិនៃ ប្រតិកម្មអាណាហ្វីឡាក់ទិច (ប្រតិកម្មអាឡឺហ្សែរ ធ្ងន់ធ្ងរ) កើតមកពីការបណ្តាលណាមួយដែលត្រូវបានពិនិត្យមើលសម្រាប់ 30 ខែ ។ អ្នកទទួលវ៉ាក់សាំងទាំងអស់ឯទៀត ត្រូវបានតាមដាន 15 នាទី ។

**តើមានបុគ្គលិកវេជ្ជសាស្ត្រនិងឧបករណ៍អ្វីខ្លះ ដែលមាននៅឯគ្លីនិកចាក់វ៉ាក់សាំងដែលមានមនុស្សច្រើន?**
កន្លែងចាក់ថ្នាំវ៉ាក់សាំងនីមួយៗមានអ្នកចាត់ចែងវ៉ាក់សាំង ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (មនុស្សដែលចាក់វ៉ាក់សាំង) ដែលអាចពិនិត្យឡើងវិញនូវសិទ្ធិរបស់បុគ្គលម្នាក់ ដើម្បីទទួលវ៉ាក់សាំងនិងឆ្លើយសំណួររបស់អ្នកជំងឺមុនពេលចាក់ ។ កន្លែងនីមួយ ៗ មានអ្នកជំនាញខាងវេជ្ជសាស្ត្រដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នឹងកន្លែងផ្តល់វ៉ាក់សាំងត្រួតពិនិត្យដំណើរការចាក់វ៉ាក់សាំង និងពិនិត្យមើលអ្នកជំងឺរយៈពេល 15-30 នាទីក្រោយមក ។

កន្លែងចាក់ថ្នាំវ៉ាក់សាំងត្រូវបានរៀបចំ ដើម្បីដោះស្រាយភាពបន្ទាន់ផ្នែកវេជ្ជសាស្ត្រនិងប្រតិកម្មមិនល្អជាមួយបុគ្គលិកពេទ្យរបស់ពួកគេនៅនឹងកន្លែង ហើយជារឿយៗមានរថយន្តសង្គ្រោះបន្ទាន់នៅនឹងកន្លែងដើម្បីជួយជាចាំបាច់ ។ ប្រសិនបើអ្នកព្រួយបារម្ភអំពីការមានប្រតិកម្មមិនល្អចំពោះវ៉ាក់សាំងដំបូងអ្នកគួរតែពិភាក្សាពីកង្វល់របស់អ្នក ជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកមុនពេលទៅដល់កន្លែង ។ អ្នកជំងឺគំរូវអោយចែកចាយវ៉ាក់សាំងនិងប្រវត្តិសុខភាពជាមួយអ្នកដែលចាក់វ៉ាក់សាំង ហើយគួរពិភាក្សាអំពីកង្វល់ឬសំណួរណាមួយជាមួយពួកគេមុនពេលចាក់វ៉ាក់សាំង ។

**តើខ្ញុំនឹងទទួលបានអ្វីដើម្បីបង្ហាញជាភ័ស្តុតាងនៃការចាក់ថ្នាំវ៉ាក់សាំង ?** (បានធ្វើបច្ចុប្បន្នភាព 9/7/21)
អ្នកគួរតែទទួលបានប័ណ្ណចាក់វ៉ាក់សាំងឬឯកសារបោះពុម្ពចេញ ដែលប្រាប់អ្នកពីវ៉ាក់សាំងការពារកូវិដ-19 ដែលអ្នកបានទទួលកាលបរិច្ឆេទ ដែលអ្នកបានទទួលនិងកន្លែងដែលអ្នកបានទទួលវា ។ សូមបញ្ជាក់ថារក្សាប័ណ្ណនេះ សម្រាប់កម្រិតទីពីររបស់អ្នក ។ អ្នកអាចយករូបថត នៃប័ណ្ណរបស់អ្នក ទុកជាសំណៅឌីជីថុលបន្ថែមមួយ ។

អ្នកគប្បីនឹងទទួលឯកសារ ឬ សំណៅអេឡិចត្រូនិច នៃឯកសារអង្គហេតុ ដែលប្រាប់អ្នកបន្ថែមទៀត អំពីវ៉ាក់សាំងកូវីដ-19 ជាក់ច្បាស់ដែលអ្នកត្រូវបានផ្តល់ឲ្យ ។ វ៉ាក់សាំងការពារកូវីដ-19 នីមួយៗ ដែលមានឯកសារអង្គហេតុផ្ទាល់ខ្លួនដែលមានព័ត៌មានដើម្បីជួយអ្នកឱ្យយល់ពី

ហានិភ័យនិងអត្ថប្រយោជន៍នៃការចាក់វ៉ាក់សាំងជាក់លាក់នោះ៖ Comirnaty/Pfizer, Moderna, និង Johnson & Johnson (Janssen)។

**តើខ្ញុំនឹងធ្វើដូចម្ដេច ប្រសិនបើខ្ញុំបាត់បង់ ប័ណ្ណកំណត់ត្រាថ្នាំវ៉ាក់សាំងរបស់ខ្ញុំ ?** (បានធ្វើបច្ចុប្បន្នភាព 8/18/21)

អ្នកមានជម្រើសមួយចំនួន ៖

1. សូមទាក់ទងអ្នកផ្ដល់សេវាថែទាំសុខភាពរបស់អ្នក ឬ ទីកន្លែងដែលអ្នកបានទទួលថ្នាំវ៉ាក់សាំង ។ ពួកគេអាចបោះពុម្ព សំណៅមួយសន្លឹកនៃកំណត់ត្រារបស់អ្នក ។
2. កំណត់ត្រារបស់អ្នកក៏នឹងមាននៅក្នុង v-safe, ប្រសិនបើអ្នកបានចុះឈ្មោះក្នុងកម្មវិធី ។
3. អ្នកអាចបំពេញទម្រង់ស្នើសុំកំណត់ត្រាចាក់វ៉ាក់សាំង ដែលផ្ញើរទៅក្រសួងសុខាភិបាលសាធារណៈរដ្ឋដោយផ្ទាល់ ។ ប្រសិនបើអ្នកប្រើទម្រង់បែបបទ នេះ អ្នកនឹងទទួលប្រវត្តិនៃការចាក់ថ្នាំវ៉ាក់សាំងពេញលេញទាំងអស់ ដែលបានទទួលមិនត្រឹមតែវ៉ាក់សាំងកូវីដ-19 ប៉ុណ្ណោះទេ ហើយវានឹងតម្រូវរហូតដល់ 6 សប្ដាហ៍ ដើម្បីទទួលបានកំណត់ត្រារបស់អ្នក ។
    - ក. សូមកត់ចំណាំថាទម្រង់បែបបទនេះត្រូវតែមានការបញ្ជាក់មុនពេលដាក់បញ្ជូន និងផ្ញើវាតាមសំបុត្រប្រៃសណីយ៍។ អ្នកនឹងទទួលបានកំណត់ត្រាជាក្រដាសអំពីការចាក់ថ្នាំបង្ការណាមួយដែលអ្នកបានទទួលដែលត្រូវបានរាយការណ៍ទៅកាន់ MIIS។ អ្នកនឹងមិនទទួលបានប័ណ្ណវ៉ាក់សាំងការពារកូវីដ-19 ទេ។

    ប្រសិនបើអ្នកត្រូវបានចាក់វ៉ាក់សាំងនៅកន្លែងចាក់វ៉ាក់សាំងដែលមានមនុស្សច្រើន សូមមើលសេចក្ដីណែនាំសម្រាប់ការស្នើសុំកំណត់ត្រាចាក់វ៉ាក់សាំង។

## ក្រោយពីទទួលវ៉ាក់សាំង

**តើខ្ញុំគួរតែធ្វើដូចម្ដេចប្រសិនបើអ្នកបានដកពិសោធន៍ រោគសញ្ញា ក្រោយពីទទួលវ៉ាក់សាំងកូវីដ-19 ?**

បុគ្គលខ្លះមានប្រតិកម្មបន្ទាប់ពីបានចាក់វ៉ាក់សាំង (ដូចជាអស់កម្លាំង ឈឺក្បាល និង ការឈឺចាប់នៅកន្លែងចាក់ថ្នាំ) ដែលជាសញ្ញាធម្មតាដែលរាងកាយរបស់អ្នកកំពុងការពារ ។ ប្រតិកម្មទាំងនេះអាចប៉ះពាល់ដល់សមត្ថភាពរបស់អ្នកក្នុងការធ្វើសកម្មភាពប្រចាំថ្ងៃ ប៉ុន្តែវាគួរតែបាត់ទៅវិញក្នុងរយៈពេលពីរបីថ្ងៃ ។ ប្រសិនបើអ្នកវិវត្តទៅជារោគសញ្ញាផ្លូវដង្ហើមដូចជា ការហៀរសំបោរ ការក្អក ឬការបាត់បង់ក្លិនឬរសជាតិអ្នកគួរតែពិចារណាធ្វើតេស្តកូវីដ-19 ឬពិគ្រោះជាមួយអ្នកផ្ដល់សេវាថែទាំសុខភាពរបស់អ្នក ។ ការកើតកូវីដ-19 អាចកើតឡើយព្រមទាំងក្រោយពីអ្នកបានទទួលវ៉ាក់សាំងរួចហើយ ។ សម្រាកនៅផ្ទះប្រសិនបើអ្នកឈឺហើយចៀសវាងពីការនៅក្បែរអ្នកដទៃទៀត ។ អ្នកគួរតែនិយាយជានិយោជករបស់អ្នកអំពីប្រតិកម្មដែលអាចកើតឡើងដល់ការងាររបស់អ្នក ។

ប្រសិនបើអ្នកមានការឈឺចាប់ឬមិនស្រួលធ្ងន់ធ្ងរសូមពិគ្រោះជាមួយអ្នកផ្ដល់សេវាថែទាំសុខភាពរបស់អ្នក ដែលអាចណែនាំឱសថដែលគ្មានវេជ្ជបញ្ជា ដូចជាថ្នាំ ibuprofen ឬ Acetaminophen ។ ដើម្បីកាត់បន្ថយការឈឺចាប់និងភាពមិនស្រួលត្រង់កន្លែងដែលអ្នកចាក់ថ្នាំ សូមក្រណាត់សើមស្អាតនិងសើមមកគ្របនៅលើកន្លែងនោះ ហើយប្រើឬធ្វើលំហាត់ដៃរបស់អ្នក ។ ដើម្បីកាត់បន្ថយភាពមិនស្រួលពីគ្រុនក្ដៅសូមផឹកទឹកឱ្យបានច្រើននិងស្លៀកសម្លៀកបំពាក់ស្រាល ។ ក្នុងករណីភាគច្រើនភាពមិនស្រួលពីគ្រុនក្ដៅ ឬការឈឺចាប់គឺជារឿងធម្មតាទេ ប៉ុន្តែសូមទាក់ទងអ្នកផ្ដល់សេវាថែទាំសុខភាពរបស់អ្នកប្រសិនបើ៖

- សម្បុរឡើងក្រហមឬឈឺនៅកន្លែង ដែលអ្នកចាក់បានកើនឡើងបន្ទាប់ពី 24 ម៉ោង
- ប្រតិកម្ម របស់អ្នកកំពុងធ្វើឱ្យអ្នកព្រួយបារម្ភ ឬហាក់ដូចជាបាត់ទៅវិញបន្ទាប់ពីពីរបីថ្ងៃ

**តើខ្ញុំអាចរាយការណ៍ដូចម្ដេចប្រសិនបើខ្ញុំមានប្រតិកម្ម ក្រោយពីការទទួលវ៉ាក់សាំងកូវីដ-19 ?**

**V-safe** គឺជាឧបករណ៍ដែលមានមូលដ្ឋានលើទូរស័ព្ទឆ្លាតដែលប្រើការផ្ញើសារនិងការស្ទង់មតិតាមអ៊ីនធឺរណែត ដើម្បីផ្តល់ការត្រួតពិនិត្យសុខភាពផ្ទាល់ខ្លួន បន្ទាប់ពីអ្នកទទួលការចាក់វ៉ាក់សាំងកូវីដ-19 ។ តាមរយៈ **v-safe** អ្នកអាចប្រាប់ CDC យ៉ាងឆាប់រហ័ស ប្រសិនបើអ្នកមានប្រតិកម្ម បន្ទាប់ពីទទួលបានវ៉ាក់សាំងកូវីដ-19 ។ ដោយផ្អែកលើចម្លើយរបស់អ្នកនរណាម្នាក់មកពី CDC អាចទូរស័ព្ទមកស៊ើបសួរអ្នកនិងទទួលបានព័ត៌មានបន្ថែម ។ ហើយ **v-safe** នឹងរំលឹកអ្នកអោយទទួលការចាក់វ៉ាក់សាំងកូវីដ-19 ជាលើកទី 2 ប្រសិនបើអ្នកត្រូវការវា ។ ដើម្បីចុះឈ្មោះជាមួយ **v-safe**, សូមចូលទៅ ការត្រួតពិនិត្យ V-safe ក្រោយពីការចាក់ថ្នាំវ៉ាក់សាំង| CDC។

ប្រសិនបើអ្នកមានកង្វល់ណាមួយ អ្នកក៏អាចទូរស័ព្ទទៅអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកបានដែរ ។ អ្នកឬអ្នកផ្តល់សេវារបស់អ្នកអាចរាយការណ៍អំពីប្រតិកម្មណាមួយទៅប្រព័ន្ធរាយការណ៍ពីប្រតិកម្មនៃវ៉ាក់សាំង (Vaccine Adverse Event Reporting System, VAERS) ដែលជាប្រព័ន្ធជាតិគ្រប់គ្រងដោយរដ្ឋាភិបាលសហព័ន្ធ ។

**តើត្រូវការរយៈពេលប៉ុន្មានមុនវ៉ាក់សាំង COVID-19 ចាប់ផ្តើមមានប្រសិទ្ធិភាព?**
ជាធម្មតាវាត្រូវការពេលពីរបីសប្តាហ៍សម្រាប់រាងកាយ ដើម្បីបង្កើតភាពស៊ាំបន្ទាប់ពីចាក់វ៉ាក់សាំង ។ នោះមានន័យថាវាអាចទៅរួច ដែលមនុស្សម្នាក់អាចឆ្លងវីរុសដែលបណ្តាលឱ្យមានកូវីដ-19 នៅ មុន ឬក្រោយពេលចាក់វ៉ាក់សាំងហើយធ្លាក់ខ្លួនឈឺ ។ នេះដោយសារតែវ៉ាក់សាំងមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីការពារ ។ អ្នកត្រូវបានគេចាត់ទុកជាថ្នាំវ៉ាក់សាំងពេញលេញប្រសិនបើអ្នកបានទទួលវ៉ាក់សាំង Moderna ឬ Pfizer COVID-19 ចំនួនពីរកម្រិតឬវ៉ាក់សាំង Janssen (Johnson និង Johnson) មួយកម្រិតកាលពីជាង 14 ថ្ងៃមុន ។

**តើការការពារពីវ៉ាក់សាំងកូវីដ-19 មានរយៈពេលប៉ុន្មាន ?**
យើងមិនទាន់មានទិន្នន័យ ដើម្បីនិយាយថា តើវ៉ាក់សាំងកូវីដ-19 នឹងផ្តល់ការការពារដល់ពេលណាទេ ។ អ្នកជំនាញកំពុងសិក្សាស្វែងយល់បន្ថែម ទាំងការការពារដល់នរណាម្នាក់ទទួលបានពីការឆ្លងរោគ (ហៅថាភាពស៊ាំធម្មជាតិ) និងការការពារអ្នកណាម្នាក់ ដែលបានទទួលពីវ៉ាក់សាំង ។

**តើខ្ញុំត្រូវការការណែនាំអ្វីខ្លះបន្ទាប់ពីខ្ញុំបានចាក់វ៉ាក់សាំងពេញលេញរួចហើយ?** (បានធ្វើឲ្យបច្ចុប្បន្នភាព 6/9/21)
បុគ្គលដែលត្រូវបានចាក់ថ្នាំពេញលេញ អាចចាប់ផ្តើមធ្វើអ្វីៗខ្លះ ដែលពួកគេបានឈប់ធ្វើ ដោយព្រោះតែរោគរាតត្បាត ។ សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅ ការដឹកនាំសម្រាប់បុគ្គលដែលបានទទួលវ៉ាក់សាំងពេញលេញជំទាស់នឹងកូវីដ-19 | Mass.gov។

## សុវត្ថិភាពវ៉ាក់សាំង

**តើវ៉ាក់សាំង Johnson & Johnson មានសុវត្ថិភាពឬទេ?**
វ៉ាក់សាំងកូវីដ-19 ទាំងអស់មានសុវត្ថិភាព និងមានប្រសិទ្ធិភាពខ្ពស់ ប្រឆាំង នឹងរោគធ្ងន់ធ្ងរ ការសម្រាកក្នុងមន្ទីរពេទ្យនិងសេចក្តីស្លាប់ ។ មានហានិភ័យមួយដែលកម្រមានប៉ុន្តែ ស្ថានភាពធ្ងន់ធ្ងរ ទាក់ទងនឹងកំណកឈាម និងមានកោសិកាឈាមទាប ក្រោយពីការទទួល វ៉ាក់សាំងកូវីដ-19 J&J ។ ហានិភ័យទាបនិងអត្ថប្រយោជន៍មានកម្រិតខ្ពស់ជាងហានិភ័យនេះ ។ សូមពិនិត្យមើល ឯកសារអង្គហេតុនេះ សម្រាប់ព័ត៌មានបន្ថែម ។

**តើយើងដឹងថាប្រសិនបើវ៉ាក់សាំងមានសុវត្ថិភាពដូចម្តេច ?**
វាចាំបាច់ត្រូវដឹងថាវ៉ាក់សាំងសាកល្បង ការសាកល្បងច្រើនជាងឱសថដទៃទៀត ។ ទីមួយក្រុមមនុស្សតូចៗទទួលវ៉ាក់សាំងសាកល្បង ។ បន្ទាប់មកវ៉ាក់សាំងត្រូវបានផ្តល់ដល់មនុស្ស ដែលមានចរិតជាក់លាក់ (ឧ. អាយុ ពូជសាសន៍ និង សុខភាពខ្លួនប្រាណ) ។ បន្ទាប់មក វ៉ាក់សាំងត្រូវបានផ្តល់ដល់ប្រជាជនរាប់ម៉ឺននាក់ ហើយត្រូវបានធ្វើតេស្តសម្រាប់ប្រសិទ្ធភាពនិងសុវត្ថិភាព ។

ក្រោយពី នោះមក គណៈកម្មារប្រឹក្សានៃការអនុវត្ត ការចាក់ថ្នាំវ៉ាក់សាំង (Advisory Committee on Immunization Practices ,ACIP) របស់CDC ពិនិត្យមើលទិន្នន័យ ដើម្បី ចង់ដឹងថាតើថ្នាំវ៉ាក់សាំងមានដំណើរការនិងសុវត្ថិភាពឬអត់ ។ ពួកគេផ្តល់ដំបូន្មានដល់រដ្ឋបាលអាហារនិងឪសថអាមេរិក (FDA) ។ រដ្ឋបាលអាហារនិងឪសថពិនិត្យមើលលើទិន្នន័យនិងដំបូន្មានពី ACIP ហើយសំរេចថាតើត្រូវអនុម័តវ៉ាក់សាំងនេះឬអត់ ។ វ៉ាក់សាំងនេះត្រូវបានអនុម័តតែបន្ទាប់ពី **ជំហានទាំងអស់នេះ**ត្រូវបានធ្វើហើយអ្នកជំនាញប្រាកដថាវាមានប្រសិទ្ធភាពនិងមានសុវត្ថិភាព ។

សូមចូលទៅ ការបញ្ជាក់សុវត្ថិភាពនៃវ៉ាក់សាំងកូវីដ-19 ក្នុងសហរដ្ឋអាមេរិក | CDC សម្រាប់ព័ត៌មានបន្ថែម ។

**តើវាមានសុវត្ថិភាពដូចម្តេច ប្រសិនបើវាបានកើតឡើងឆាប់រហ័សពេក ?**
ការកំណត់ពេលវេលាដើម្បីបង្កើតវ៉ាក់សាំង កូវីដ-19 ត្រូវបានបង្កើតឡើង ប៉ុន្តែមិនដែលកាត់បន្ថយសុវត្ថិភាពទេ ។ នេះគឺជាវិធី ៖

1. **យើងបានមានព័ត៌មានសំខាន់ចាំបាច់រួចហើយ ៖** វីរុសកូវីដ-19 គឺជាផ្នែកមួយនៃក្រុមដែលមានមេរោគឆ្លងដែលត្រូវបានសិក្សាអស់រយៈពេលជាយូរមកហើយ ។ ក្រុមអ្នកជំនាញបានរៀនព័ត៌មានសំខាន់ៗពីការផ្ទុះឡើងនៃវីរុសកូរ៉ូណាដទៃទៀត ដែលជួយពួកគេឱ្យបង្កើតវ៉ាក់សាំងការពារកូវីដ-19 ដូច្នេះយើងមិនបានចាប់ផ្តើមដោយដៃទទេឡើយ ។
2. **រដ្ឋាភិបាល បានផ្តល់មូលនិធិ ចំពោះការស្រាវជ្រាវនៃវ៉ាក់សាំង ៖** សហរដ្ឋអាមេរិកនិងរដ្ឋាភិបាលដទៃទៀតបានវិនិយោគប្រាក់យ៉ាងច្រើន ដើម្បីគាំទ្រក្រុមហ៊ុនវ៉ាក់សាំងជាមួយភារកិច្ចរបស់ពួកគេ ។ ការធ្វើការរួមគ្នាជាមួយប្រទេសដទៃទៀតក៏បានជួយអ្នកស្រាវជ្រាវអោយធ្វើចលនាបានលឿនដែរ ។
3. **មានមនុស្សជាច្រើនរូបដែលបានចូលរួមក្នុងការសាកល្បងស្រាវជ្រាវ ៖** បុគ្គលជាច្រើនចប់បានជំនួយដោយបានចូលរួមក្នុងការសិក្សាស្រាវជ្រាវវ៉ាក់សាំង ។ ក្រុមហ៊ុនមិនត្រូវចំណាយពេលវេលាស្វែងរកអ្នកស្ម័គ្រចិត្តឡើយ ។
4. **ការផលិត បានកើតឡើងក្នុងពេលជាមួយគ្នា នឹងការសិក្សាស្រាវជ្រាវអំពីសុវត្ថិភាព ៖** ក្រុមហ៊ុនចាក់វ៉ាក់សាំងអាចបង្កើតនិងរក្សាទុកវ៉ាក់សាំងជាច្រើន ក្នុងពេលតែមួយនៅពេលការសិក្សា (ហៅថាការសាកល្បងព្យាបាល) ដែលកំពុងកើតឡើង ដើម្បីបង្ហាញថាវ៉ាក់សាំងមានសុវត្ថិភាពនិងប្រសិទ្ធភាព ។ នេះមានន័យថាវ៉ាក់សាំងត្រូវបានត្រៀមរួចរាល់ ដើម្បីចែកចាយនៅពេលដែលវាត្រូវបានអនុម័ត ។

**តើវាមានសុវត្ថិភាពឬទេ ប្រសិនបើយើងមិនដឹងអំពីប្រតិកម្មអំឡុងពេលយូរ ?**
វ៉ាក់សាំងកូវីដ-19 Pfizer និង Moderna គឺជាអ្វីដែល អ្នកជំនាញហៅថាវ៉ាក់សាំង RNA ឬវ៉ាក់សាំង mRNA ក្នុង នាមកាត់ខ្លី។ វ៉ាក់សាំង Janssen (Johnson & Johnson) ត្រូវបានគេហៅថា វ៉ាក់សាំងវេកទ័រវីរុស ។ វ៉ាក់សាំងទាំងពីរប្រភេទត្រូវបានសិក្សានៅក្នុងការសាកល្បងទៅលើសត្វនិងមនុស្សអស់រយៈពេលជាច្រើនឆ្នាំ ។ ម៉្យាងវិញទៀតកូវីដ-19 មានរយៈពេល ប្រហែលមួយឆ្នាំ ហើយប្រតិកម្មយូរអង្វែងនៃការឆ្លងមេរោគកូវីដ-19 ភាគច្រើនមិនត្រូវបានគេដឹងហើយអាចភាពធ្ងន់ធ្ងរ ។ ដូច្នេះការចាក់វ៉ាក់សាំងគឺជាជំរើសល្អបំផុតសម្រាប់សុខភាពនិងសុវត្ថិភាពរយៈពេលវែង ។

អ្នកជំនាញនឹងបន្តតាមដានពី ប្រតិកម្មនៃវ៉ាក់សាំងកូវីដ-19 ។ បុគ្គលនៅក្នុងការសាកល្បងព្យាបាលនឹងត្រូវបានគេតាមដានរយៈពេល 2 ឆ្នាំ ។ បុគ្គលដទៃទៀត ដែលទទួលវ៉ាក់សាំងអាចប្រើប្រាស់ ឧបករណ៍ដែលមានឈ្មោះថា v-safe នៅលើទូរស័ព្ទឆ្លាតរបស់ពួកគេ ដើម្បីប្រាប់ CDC យ៉ាង ឆាប់រហ័ស ប្រសិនបើអ្នកមានប្រតិកម្មបន្ទាប់ពីទទួលបានវ៉ាក់សាំង កូវីដ-19 ។ អ្នកប្រើប្រាស់ V-safe អាចចែករំលែកព័ត៌មានសម្រាប់រហូតដល់មួយឆ្នាំ ក្រោយពីវ៉ាក់សាំងរបស់ពួកគេ ។ រៀនបន្ថែមទៀតនៅ cdc.gov/vsafe។

**តើវ៉ាក់សាំងកូវីដ-19 មានប្រតិកម្មណាមួយឬទេ ?**

មនុស្សមួយចំនួនអាចប្រតិកម្មបន្ទាប់ពីបានចាក់វ៉ាក់សាំងដែលជាសញ្ញាធម្មតាដែលខ្លួនប្រាណរបស់អ្នកកំពុងការពារ ។ ប្រតិកម្មទាំងនេះអាចប៉ះពាល់ដល់សមត្ថភាពរបស់អ្នកក្នុងការធ្វើសកម្មភាពប្រចាំថ្ងៃ ប៉ុន្តែវាគួរតែបាត់ទៅវិញក្នុងរយៈពេលពីរបីថ្ងៃ ។ ប្រតិកម្មទូទៅបំផុតគឺមានលក្ខណៈតូចតាចនិងរួមមានការនឿយហត់ ការឈឺក្បាល ការឈឺចាប់នៅកន្លែងចាក់ថ្នាំ សាច់ដុំ និង / ឬការឈឺសន្លាក់ ការញាក់ ការក្អួតចង្អោរនិង / ឬការក្អួតនិងគ្រុន។

**តើវ៉ាក់សាំង កូវីដ-19 អាចធ្វើឲ្យខ្ញុំឈឺនឹងជម្ងឺ កូវីដ-19 ឬទេ ?**
ទេ ។ វ៉ាក់សាំង Pfizer, Moderna, និង Janssen (Johnson & Johnson) មិនមែនវីរុស រស់រវើក ដែលបណ្តាលឲ្យមានកូវីដ-19 ទេ ។ នេះមានន័យថាវ៉ាក់សាំងកូវីដ-19 មិនអាចធ្វើឲ្យអ្នកឈឺជាមួយកូវីដ-19 ឡើយ ។ (ធនធាន ៖ អង្គហេតុអំពីវ៉ាក់សាំងកូវីដ-19 (cdc.gov)។ ដូច្នេះហើយ ប្រសិនបើអ្នកតេស្តឃើញថាមានវិជ្ជមានចំពោះកូវីដ-19 ថ្វីបើអ្នកបានទទួលវ៉ាក់សាំង ក្តី អ្នកត្រូវតែញែកខ្លួនចេញ ។

**តើបុគ្គលម្នាក់ ដែលមានប្រវត្តនៃអាឡឺហ្សែរ គួរតែទទួលវ៉ាក់សាំងកូវិដ-19 ឬទេ ?**
អ្នកមិនគួរចាក់វ៉ាក់សាំង Pfizer, Moderna, ឬ Janssen (Johnson និង Johnson) COVID-19 ប្រសិនបើអ្នកមានប្រវត្តិនៃប្រតិកម្មអាឡែហ្ស៊ីធ្ងន់ធ្ងរ (ហៅផងដែរថាអាណាហ្វីឡាក់ទិច) ចំពោះគ្រឿងផ្សំណាមួយនៅក្នុងវ៉ាក់សាំង ។ ប្រសិនបើអ្នកមានប្រវត្តិប្រតិកម្មអាឡែស៊ីធ្ងន់ធ្ងរទៅនឹងអ្វីផ្សេងទៀតដែលមិនមាននៅក្នុងវ៉ាក់សាំង សូមពិភាក្សាជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកមុនពេលទទួលថ្នាំវ៉ាក់សាំង ។

ទោះបីជាមានឱកាសតិចតួចដែលវ៉ាក់សាំងកូវីដ-19 អាចបង្កឱ្យមានប្រតិកម្មអាលែហ្ស៊ីធ្ងន់ធ្ងរក៏ដោយ នេះច្រើនតែកើតឡើងក្នុងរយៈពេលពីរបីនាទីទៅមួយម៉ោង បន្ទាប់ពីទទួលថ្នាំវ៉ាក់សាំង។
មនុស្សគ្រប់គ្នាទោះបីពួកគេមិនមានអាឡែរហ្ស៊ីក៏ដោយ ក៏ត្រូវបានតាមដានយ៉ាងហោចណាស់ 15 នាទីបន្ទាប់ពីទទួលបានវ៉ាក់សាំងកូវីដ-19 ។

**តើខ្ញុំគួរតែទៅមន្ទីរគ្លីនិកចាក់ថ្នាំវ៉ាក់សាំង ដែលមានមនុស្សច្រើនឬប្រសិនបើខ្ញុំមានប្រវត្តិនៃប្រតិកម្មអាឡឺហ្សែរធ្ងន់ធ្ងរ ?**
កន្លែងចាក់វ៉ាក់សាំងទាំងអស់អាចតបតទៅនឹងប្រតិកម្មអាលែហ្ស៊ីធ្ងន់ធ្ងរដ៏កម្រមាននិងប្រតិកម្មអាណាហ្វីឡាក់ទិចដែលអាចកើតមានបន្ទាប់ពីការចាក់វ៉ាក់សាំង ។ ប្រសិនបើអ្នកមានប្រតិកម្មអាឡែហ្ស៊ីធ្ងន់ធ្ងរឬភ្លាមៗចំពោះកម្រិតទីមួយ អ្នកមិនគួរទទួលការចាក់លើកទីពីរទេ ។ អ្នកដែលមានប្រតិកម្មអាឡែហ្ស៊ីធ្ងន់ធ្ងរទៅនឹងវ៉ាក់សាំងផ្សេងទៀត ឬថ្នាំចាក់ដែលចាក់បញ្ចូលគួរតែប្រាប់បុគ្គលិកនៅគ្លីនិកចាក់វ៉ាក់សាំងជាមុន មុនពេលចាក់ថ្នាំ ។ អ្នកក៏ប្រហែលជាចង់ពិភាក្សាអំពីការចាក់វ៉ាក់សាំងកូវីដ-19 ជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក មុនពេលទៅលេង ។

**តើគ្រឿងផ្សំក្នុងវ៉ាក់សាំងមានអ្វីខ្លះ?** (ធ្វើបច្ចុប្បន្នភាព 9/7/21)
វ៉ាក់សាំងមិនមានស៊ុត ជែលលីនថែល គឺមិការពារឬជ័រ។ ឯកសារអង្គហេតុវ៉ាក់សាំង កូវីដ-19 សម្រាប់អ្នកទទួលនិងអ្នកផ្តល់ការថែទាំ មានគ្រឿងផ្សំនៃវ៉ាក់សាំងនីមួយៗ នៅទំព័រ 2-3៖ Comirnaty/Pfizer, Moderna, និង Johnson & Johnson (Janssen)។

**ខ្ញុំចង់មានកូនថ្ងៃណាមួយ ។ តើវាមានសុវត្ថិភាពសម្រាប់ខ្ញុំដើម្បីទទួលវ៉ាក់សាំងកូវីដ-19 ?**
(បានធ្វើឲ្យមានបច្ចុប្បន្នភាព 8/18/21)
មែនហើយ ។ CDC ណែនាំឱ្យបុគ្គលដែលចង់មានផ្ទៃពោះនៅពេលឥឡូវនេះ ឬដែលអាចនឹងមានផ្ទៃពោះនាពេលអនាគតទទួលការចាក់វ៉ាក់សាំងការពារកូវីដ-19។ មិនមានភ័ស្តុតាងបញ្ជាក់ទេថាអង្គបដិប្រាណដែលបង្កើតឡើងបន្ទាប់ពីការចាក់វ៉ាក់សាំងការពារកូវីដ-19 ឬថាធាតុផ្សំរបស់វ៉ាក់សាំងនឹងបង្កឱ្យមានបញ្ហាណាមួយជាមួយនឹងការក្លាយជាមានផ្ទៃពោះនៅពេលឥឡូវនេះ ឬនៅពេលអនាគតនោះទេ។

តាមពិតទៅគ្មានភស្តុតាងបញ្ជាក់ណាមួយថាវាល់វ៉ាក់សាំង ទាំងឡាយរួមទាំងវ៉ាក់សាំងការពារកូវីដ-19 បង្កបញ្ហាដល់ការមានកូនចំពោះស្ត្រី ឬបុរសឡើយ។ ស្វែងយល់បន្ថែមនៅវ៉ាក់សាំងការពារកូវីដ-19 សម្រាប់អ្នកដែលចង់មានកូន | CDC។

**តើអ្នកដែលមានផ្ទៃពោះ ឬបំបៅដោះកូនអាចទទួលវ៉ាក់សាំង កូវីដ-19 ?** (បានធ្វើឲ្យបច្ចុប្បន្នភាព 8/18/21)
មែនហើយ ។ CDC និងមហាវិទ្យាល័យវេជ្ជបណ្ឌិតជំនាញខាងរោគស្ត្រី និងរោគស្ត្រីអាមេរិកាំង សូមផ្ដល់ជាយោបល់ឲ្យមានការចាក់វ៉ាក់សាំងកូវីដ-19 សម្រាប់បុគ្គលដែលមានផ្ទៃពោះ ឬបំបៅដោះ ។ ការឆ្លងមេរោគកូវីដ-19 ក្នុងពេលមានផ្ទៃពោះបង្កើនហានិភ័យនៃជំងឺធ្ងន់ធ្ងរ និងការកើតមិនគ្រប់ខែ ។ ភស្តុតាងបញ្ជាក់អំពីសុវត្ថិភាព និងប្រសិទ្ធភាពនៃការចាក់វ៉ាក់សាំងការពារកូវីដ-19 អំឡុងពេលមានផ្ទៃពោះកំពុងមានការកើនឡើង។ ទិន្នន័យបង្ហាញថាអត្ថប្រយោជន៍នៃការទទួលវ៉ាក់សាំងការពារកូវីដ-19 លើសពីហានិភ័យដែលអាចដឹង ឬអាចកើតមានឡើងនៃការចាក់វ៉ាក់សាំង អំឡុងពេលមានផ្ទៃពោះ។

ការទទួលថ្នាំវ៉ាក់សាំងគឺជាជម្រើសផ្ទាល់ខ្លួនសម្រាប់មនុស្សដែលមានផ្ទៃពោះឬ ការបំបៅដោះ ប្រសិនបើអ្នកមានសំណួរ សូមពិភាក្សាអំពីការចាក់វ៉ាក់សាំងជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក។

**តើវ៉ាក់សាំងកូវីដ-19 មានសុវត្ថិភាពសម្រាប់កុមារឬទេ ?** (បានធ្វើបច្ចុប្បន្នភាព 9/7/21)
នៅពេលនេះវ៉ាក់សាំង Pfizer ត្រូវបានអនុញ្ញាតសម្រាប់មនុស្សដែលមានអាយុចាប់ពី 12 ឆ្នាំឡើងទៅ (និងមានការឯកភាពពេញលេញសម្រាប់មនុស្សដែលមានអាយុ 16ឆ្នាំឡើងទៅ) ហើយវ៉ាក់សាំង Moderna និង Janssen (Johnson និង Johnson) ត្រូវបានអនុញ្ញាតសម្រាប់មនុស្សដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ ។ កុមារតូចនិងក្មេងជំទង់មិនគួរទទួលការចាក់វ៉ាក់សាំងកូវីដ-19 នៅពេលនេះទេ ។

**តើវ៉ាក់សាំងកូវីដ-19 ផ្លាស់ប្តូរ DNA របស់ខ្ញុំឬទេ ?**
ទេ ។ វ៉ាក់សាំងកូវីដ-19 មិនផ្លាស់ប្តូរឬ អន្តរកម្មជាមួយឌីអិនអេរបស់អ្នកតាមរបៀបណាមួយឡើយ ។

វ៉ាក់សាំងបង្រៀនប្រព័ន្ធភាពស៊ាំរបស់យើង ពីរបៀបប្រយុទ្ធប្រឆាំងនឹងវីរុសជាក់លាក់ ។ ពួកវាធ្វើការជាមួយការការពារធម្មជាតិរបស់រាងកាយ ដើម្បីអភិវឌ្ឍភាពស៊ាំទៅនឹងជំងឺ ។  ដើម្បីបំពេញការងាររបស់ខ្លួនវ៉ាក់សាំងការពារកូវីដ-19 មិនចាំបាច់ចូលទៅក្នុងកោសិកាដែលជាកន្លែងផ្ទុកឌីអិនអេរបស់យើងទេ ។ នេះមានន័យថាវ៉ាក់សាំងមិនដែលមានអន្តរកម្មជាមួយឌីអិនអេរបស់យើង តាមវិធីណាទេហើយគ្មានវិធីដើម្បីផ្លាស់ប្តូរវាទេ ។

នៅចុងបញ្ចប់នៃដំណើរការខ្លួនប្រាណរបស់យើងបានរៀនពីរបៀបការពារប្រឆាំងនឹងការឆ្លងនាពេលអនាគត ។ ការឆ្លើយតបភាពស៊ាំនិងការបង្កើតអង្គបដិប្រាណគឺជាអ្វីដែលការពារយើងពីការឆ្លងមេរោគ ប្រសិនបើវីរុសពិតចូលក្នុងខ្លួនរបស់យើង ។ (ធនធាន ៖ ឯកសារអង្គហេតុអំពីវ៉ាក់សាំងកូវីដ-19 (cdc.gov)

**តើវ៉ាក់សាំងត្រូវបានតេស្តលើអ្នកណា ?**
សុវត្ថិភាពនៃវ៉ាក់សាំងកូវីដ-19 Pfizer  ត្រូវបានវាយតម្លៃលើមនុស្សដែលមានអាយុចាប់ពី 16 ឆ្នាំឡើងទៅនៅក្នុងការសិក្សាផ្នែកវេជ្ជសាស្ត្រចំនួនពីរ ដែលធ្វើឡើងនៅសហរដ្ឋអាមេរិក អឺរ៉ុប ទួរគី អាហ្វ្រិក ខាងត្បូងនិងអាមេរិកខាងត្បូង ។ សរុបទៅ 50.6% នៃអ្នកចូលរួមជាបុរសនិង 49.4% ជាស្ត្រី 83.1% ជាជនជាតិស្បែកស 9.1% ជាជនជាតិស្បែកខ្មៅឬជនជាតិអាហ្វ្រិកអាមេរិក 28.0% ជាជនជាតិអេស្ប៉ាញឬអាមេរិកឡាទីន 4.3% ជាជនជាតិអាស៊ីនិង 0.5% ជាជនជាតិ

អាមេរិកាំងស្បែកក្រហមឬអាឡាស្កា ។ សុវត្ថិភាពនៃវ៉ាក់សាំង Pfizer ចំពោះក្មេងជំទង់វ័យក្មេង ត្រូវបានសិក្សាលើមនុស្សវ័យជំទង់ 2,260 នាក់ដែលមានអាយុពី 12-15 ឆ្នាំនៅសហរដ្ឋអាមេរិក។ ឯកសារអង្គហេតុ EUA វ៉ាក់សាំងកូវីដ-19 Pfizer-BioNTech)

សុវត្ថិភាពនៃវ៉ាក់សាំងកូវីដ-19 Moderna ត្រូវបានវាយតម្លៃទៅលើមនុស្សដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅនៅក្នុងសហរដ្ឋអាមេរិក ។ សរុបទៅចំនួន 52.7% នៃអ្នកចូលរួមជាបុរស, 47.3% ជាស្ត្រី, 79.2% ជាជនជាតិស្បែកស, 10.2% ជាជនជាតិស្បែកខ្មៅឬជនជាតិអាហ្វ្រិកអាមេរិក, 20.5% ជាជនជាតិអេស្ប៉ាញឬឡាទីន, 4.6% ជាជនជាតិអាស៊ី, .08% ជាជនជាតិឥណ្ឌា អាមេរិកាំងស្បែកក្រហមឬអាឡាស្កា, 0.2% ជាអ្នកកោះហាវ៉ៃដើម ឬជាកោះប៉ាស៊ីហ្វិក 2.1% ជាអ្នកផ្សេងនិង 2.1% ជាជនពហុសាស្ត្រ ។ (ឯកសារអង្គហេតុ EUA វ៉ាក់សាំង កូវីដ-19 Moderna សម្រាប់អ្នកផ្តល់សេវាថែទាំសុខភាព

សុវត្ថិភាពនៃវ៉ាក់សាំង Janssen (Johnson & Johnson) ត្រូវបានវាយតម្លៃលើមនុស្សដែលមានអាយុចាប់ពីអាយុ 18 ឆ្នាំឡើងទៅនៅសហរដ្ឋអាមេរិក ប្រេស៊ីល អាហ្វ្រិក ខាងត្បូងកូឡុំប៊ី អាហ្សង់ទីន ប៉េរូឈីលីនិងម៉ិកស៊ិក ។ សរុបទៅ 45% អ្នកចូលរួមជាស្ត្រី 55% ជាបុរស 58.7% ជាជនជាតិស្បែកស 19.4% ជាជនជាតិស្បែកខ្មៅឬអាហ្វ្រិកអាមេរិក 45.3% ជាជនជាតិអេស្ប៉ាញ ឬអាមេរិកឡាទីន 3.3% ជាជនជាតិអាស៊ី 9.5% ជាជនជាតិស្បែកក្រហម / អាឡាស្កា 0.2% ជាជនជាតិកោះប៉ាស៊ីហ្វិក 5.6% ជាក្រុមជនជាតិផ្សេងៗគ្នានិង 1.4% ជាក្រុមដែលមិនស្គាល់អត្តសញ្ញាណ (ឯកសារអង្គហេតុEUA វ៉ាក់សាំងកូវីដ-19 សម្រាប់អ្នកផ្តល់សេវាថែទាំសុខភាព)

## ព័ត៌មានបន្ថែម

សូមចូលមើលគេហទំព័រមាននៃមជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការរោគ (CDC) ដែលបានធ្វើបច្ចុប្បន្នភាពជាប្រចាំលើការចាក់វ៉ាក់សាំងការពារកូវីដ-19៖

- អត្ថប្រយោជន៍នៃការទទួលវ៉ាក់សាំងកូវីដ-19
- របៀបដែលវ៉ាក់សាំងកូវីដ-19 មានដំណើរការ
- ពាក្យចចាមអារាម និងការយល់ច្រឡំអំពីវ៉ាក់សាំងកូវីដ-19
- សំណួរបានសួរជាញឹកញាប់ អំពីការចាក់ថ្នាំវ៉ាក់សាំង កូវីដ-19